## ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងមហាផ្ទៃ

សាលាខេត្តពោធិ៍សាត់

លេខ ៤៦ គសណ/ពស

ពោធិ៍សាត់ ថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ២០១៥

# សេចក្តីជូនដំណឹង

## ស្តីពីការរៀបចំបញ្ជីឈ្មោះអ្នកទទួលការលទ្ធកម្មគម្រោងឃុំ សង្កាត់ឆ្នាំ២០១៦

រដ្ឋបាលខេត្តពោធិ៍សាត់ មានកិត្តិយសសូមជម្រាបជូនអ្នកទទួលការទាំងអស់ឲ្យបានជ្រាបថា នៅក្នុងខែតុលាឆ្នាំ២០១៥ខាងមុខនេះ នឹងមានរៀបចំបញ្ជីឈ្មោះអ្នកទទួលការឆ្នាំ២០១៦ សម្រាប់ដេញថ្លៃគម្រោងមូលនិធិឃុំ សង្កាត់ឆ្នាំ២០១៦។ អ្នកទទួលការដែលមានឈ្មោះក្នុងបញ្ជីឈ្មោះអ្នកទទួលការមានសិទ្ធិដាក់សំណើដេញថ្លៃគ្រប់គម្រោងមូលនិធិ ឃុំ សង្កាត់ ទាំងអស់នៅទូទាំងព្រះរាជាណាចក្រកម្ពុជា។

អ្នកទទួលការសម្រាប់គម្រោងហេដ្ឋារចនាសម្ព័ន្ធត្រូវបានបែងចែកជា០៣ប្រភេទ ៖

- ប្រភេទទី១ ៖ អ្នកទទួលការសំណង់ទូទៅ ( ការងារសំណង់អគារ និងការងារបេតុង ...។ល។)
- ប្រភេទទី២ ៖ អ្នកទទួលការការងារដី (ប្រឡាយ ទំនប់ ផ្លូវដីស ផ្លូវក្រួសក្រហម ...។ល។)
- ប្រភេទទី៣ ៖អ្នកទទួលការឯកទេស(អ្នកទទួលការដែលមានឧបករណ៍និងជំនាញបច្ចេកទេសសម្រាប់ការងារពិសេស ឧទាហរណ៍ អណ្តូងស្នប់ ...។ល។)

អ្នកទទួលការសម្រាប់គម្រោងសេវាកម្មត្រូវបានបែងចែកជា០៣ប្រភេទ ៖

- ប្រភេទទី១ ៖ អ្នកផ្តល់សេវារៀបចំសហគមន៍ ( ជលផល ព្រៃឈើ ទេសចរណ៍ ធម្មជាតិអក្សរកម្ម.....។ល។)
- ប្រភេទទី២ ៖ អ្នកផ្តល់សេវាបច្ចេកទេសកសិកម្ម( ការដាំដុះដំណាំ ការចិញ្ចឹមសត្វ ការចិញ្ចឹម ត្រី...។ល។)
- ប្រភេទទី៣ ៖ អ្នកផ្តល់សេវាសិប្បកម្ម ( ត្បាញកន្ទេល កែច្នៃអនុផលព្រៃឈើ កែច្នៃចំណីអាហារ......។ល។)

អ្នកទទួលការ អ្នកផ្តល់សេវា ត្រូវមានបុគ្គលិកបច្ចេកទេស និងសម្ភារៈ បរិក្ខាគ្រប់គ្រាន់ ដូចមានបរិយាយនៅក្នុងពាក្យសុំចុះឈ្មោះក្នុងបញ្ជីឈ្មោះអ្នកទទួលការ ដើម្បីអនុវត្តការងារទៅតាមប្រភេទដែលបានស្នើសុំ និងត្រូវមានបទពិសោធន៍អនុវត្តគម្រោងទាក់ទងនឹងប្រភេទនីមួយៗដែលបានស្នើសុំយ៉ាងតិច០២ ក្នុងអំឡុងពេល៥ឆ្នាំចុងក្រោយ។ បន្ថែមលើនេះអនុគណៈកម្មការបុរេលក្ខណៈសម្បត្តិនឹងចុះពិនិត្យវាយតម្លៃ ដល់ទីតាំងក្រុមហ៊ុនរបស់អ្នកទទួលការ ដោយវាយតម្លៃសមត្ថភាពបច្ចេកទេស និងសម្ភារៈបរិក្ខាដោយផ្អែកលើលក្ខណៈវិនិច្ឆ័យដូចមានបរិយាយនៅក្នុងពាក្យសុំចុះបញ្ជី ព្រមទាំងពិនិត្យមើលគុណភាពការងារ ភាពស្មោះត្រង់ ការអនុវត្តការងារទាន់ពេលវេលា និងកិច្ចសហប្រតិបត្តិការ របស់អ្នកទទួលការជាមួយម្ចាស់គម្រោង ដោយផ្អែកលើកំណត់ត្រាកន្លងមក។ លទ្ធផលនៃការវាយតម្លៃនេះ អនុគណៈកម្មការបុរេលក្ខណៈសម្បត្តិនឹងរៀបចំដាក់ជូន អភិបាល នៃគណៈអភិបាលខេត្ត ដើម្បីពិនិត្យ និងសម្រេច។ អ្នកទទួលការ និងអ្នកផ្តល់សេវាទាំងឡាយណា ដែលត្រូវបានរកឃើញថាមានការពាក់ព័ន្ធនឹងការឃុបឃិតស៊ីគ្រលំគ្នាដូចជា ការក្លែងបន្លំឯកសារ និងអំពើពុករលួយផ្សេងៗទៀត នឹងត្រូវបានដកសិទ្ធិជាផ្លូវការ អ្នកទទួលការនោះនឹងមិនត្រូវបានពិចារណាក្នុងការបញ្ចូលឈ្មោះទៅក្នុងបញ្ជីឈ្មោះអ្នកទទួលការឡើយ។

អាស្រ័យហេតុនេះ បើអ្នកទទួលការមានបំណងចុះឈ្មោះក្នុងបញ្ជីឈ្មោះអ្នកទទួលការ សូមប្រញាប់មកដាក់ពាក្យសុំចុះឈ្មោះក្នុងបញ្ជីឈ្មោះអ្នកទទួលការ ចាប់ពីថ្ងៃជូនដំណឹងនេះរហូតដល់**ថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៥ វេលាម៉ោង១៧.០០នាទី**។ ចំពោះអ្នកទទួលកាដែលមានឈ្មោះក្នុងបញ្ជីឆ្នាំកន្លងមកក៏ត្រូវដាក់ពាក្យសុំចុះឈ្មោះក្នុងបញ្ជីឈ្មោះអ្នកទទួលការជាថ្មីឡើងវិញដែរ។ អ្នកទទួលការអាចមកយកពាក្យសុំចុះឈ្មោះក្នុងបញ្ជីឈ្មោះអ្នកទទួលការ នៅទីចាត់ការផែនការ និងវិនិយោគ នៃសាលាខេត្តពោធិ៍សាត់ ដោយឥតបង់ថ្លៃឬអាចទាញយកពីក្នុងគេហទំព័ររបស់គ.ជ.អ.ប( www.ncdd.gov.kh )។/

**ត.ប អភិបាល នៃគណៈអភិបាលខេត្ត**

**នាយករដ្ឋបាល**

**ម៉ុំ ម៉ានិត**